

© Laszlo Mates

# ចក្ខុវិស័យស្តីពីយេនឌ័រ និងដីធ្លី ក្នុងតំបន់មេគង្គ

## ខ្លឹមសារសង្ខេប

## សាវតារ

សមធម៌យេនឌ័រ គឺជាផ្នែកមួយដ៏មានសារៈសំខាន់ចំពោះអភិបាលកិច្ចល្អក្នុងវិស័យដីធ្លី សមធម៌យេនឌ័រផ្តោតសំខាន់លើភាពយុត្តិធម៌។ អភិបាលកិច្ចដីធ្លីប្រកបដោយសមធម៌យេនឌ័រ ធានាថាបុរស និងស្ត្រីអាចចូលរួមដោយស្មើភាពគ្នានៅក្នុងទំនាក់ទំនងរបស់ពួកគេចំពោះបញ្ហាដីធ្លី ទាំងតាមរយៈស្ថាប័នផ្លូវការ ការគ្រប់គ្រង និងរដ្ឋបាលដីធ្លីក្រៅផ្លូវការ។ មានន័យថាដំណើរការ និងស្ថាប័នអភិបាលកិច្ចកាន់កាប់ដីធ្លីត្រូវមានតម្លាភាព មានការប្រឹក្សាយោបល់ មានការចូលរួម មិនថាផលប្រយោជន៍ តម្រូវការ និងអាទិភាពផ្សេងៗគ្នារបស់ពួកគេទាក់ទងនឹងបញ្ហាដីធ្លីត្រូវបានដោះស្រាយដោយមិនគិតអំពីភេទឡើយ។ វាក៏មានសារៈសំខាន់ផងដែរចំពោះការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

ចក្ខុវិស័យ ស្តីពីយេនឌ័រនិងដីធ្លីនៅតំបន់មេគង្គ បានកំណត់អាទិភាពជាយុទ្ធសាស្ត្រ ដើម្បីពង្រឹងអភិបាលកិច្ចដីធ្លីប្រកបដោយសមធម៌យេនឌ័រនៅទូទាំងតំបន់។ ចក្ខុវិស័យផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការណែនាំពីគោលនយោបាយ និងសកម្មភាពសក្តានុពលនានា។ ចាប់ផ្តើមកំណត់ពីយេនឌ័រ និងដីធ្លីនៅក្នុងតំបន់មេគង្គ (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) ក្នុងបរិបទទស្សនៈអន្តរជាតិ និងតំបន់ ហើយបន្ទាប់មកពិនិត្យមើលគោលនយោបាយក្របខ័ណ្ឌច្បាប់នានាដែលទាក់ទងដីធ្លី និងបទប្បញ្ញត្តិយេនឌ័រជាក់លាក់របស់ប្រទេសពួកគេ។ ទាំងអស់នេះរាប់បញ្ចូលទាំងការពិនិត្យមើលច្បាប់គ្រួសារ ច្បាប់កេរមរតក ជាមួយការចុះបញ្ជីដីធ្លី និងគំនិតផ្តួចផ្តើម ផ្តល់ប័ណ្ណកម្មសិទ្ធិ ក៏ដូចជាបញ្ហានៃការអនុវត្តច្បាប់ផងដែរ។ បញ្ហាសេដ្ឋកិច្ចទាក់ទងនឹងដីធ្លី ក៏ត្រូវបានលើកយកមកបកស្រាយកាន់តែទូលំទូលាយ ក្នុងនោះរួមទាំងការកាន់កាប់ដីក្នុងទ្រង់ទ្រាយធំ ដោយរួមបញ្ចូលផលិតកម្មកសិកម្មទៅក្នុងទីផ្សារក្នុងតំបន់ និងពិភពលោក ជាមួយបញ្ហាស្ថាប័នសំខាន់ៗដែលទាក់ទងនឹងការចូលរួមនៅក្នុងអភិបាលកិច្ចដីធ្លី សិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិកាន់កាប់ដីធ្លីតាមបែបប្រពៃណី។ ប្រធានបទដែលកំពុងកើតឡើងទាំងអស់នេះត្រូវបានដកស្រង់ និងត្រូវបានផ្តល់អនុសាសន៍ផងដែរ។

## បរិបទគោលនយោបាយតំបន់ និងអន្តរជាតិ

នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះបញ្ហាយេនឌ័រនិងបញ្ហាដីធ្លីបានក្លាយជាប្រធានបទដ៏ក្តៅនៅក្នុងរបៀបវារៈគោលនយោបាយសកល។ ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម មានគន្លងអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា និងមានភូមិសាស្រ្តចម្រុះដែលគ្របដណ្តប់អ្វីៗគ្រប់យ៉ាងចាប់ពីតំបន់ព្រៃភ្នំរហូតដល់តំបន់វាលស្រែទំនាប។ ផ្ទុយមកវិញ ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចមានភាពខុសប្លែកគ្នានៅក្នុងតំបន់ ខណៈបញ្ហាយេនឌ័រមានភាពស្រដៀងគ្នាជាច្រើន ហើយក្រុមស្ត្រីជនជាតិដើមភាគតិច គឺភាគច្រើនជាជនរងគ្រោះដែលត្រូវបានគេរើសអើងបំផុត។

យេនឌ័រ និងអភិបាលកិច្ចដីធ្លីត្រូវបានបង្កើតឡើងជាលក្ខណៈអន្តរជាតិនៅក្នុងសេចក្តីណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ជលផល និងធនធានព្រៃឈើនៅក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ (VGGTs) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(គ.អ.ច) និងអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ("ស៊ី-ដ")។ គ្រប់ភាគីនៃ ("ស៊ី-ដ") ដែលរាប់បញ្ចូលទាំងភាគីនៅក្នុងតំបន់មេគង្គបានយល់ព្រមថ្កោលទោសលើការរើសអើងលើស្ត្រីភេទគ្រប់ទម្រង់ និងបន្តគោលនយោបាយនៃការលុបបំបាត់តាមគ្រប់មធ្យោបាយសមស្របរបស់ខ្លួន និងដោយគ្មានការពន្យារពេល។ នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) គោលនយោបាយក្របខ័ណ្ឌដ៏មានសារៈសំខាន់នោះគឺសេចក្តីប្រកាសឆ្នាំ២០១៧ សេចក្តីថ្លែងការណ៍ស្តីពីការអនុវត្តការឆ្លើយតបយេនឌ័រនៃចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(គ.អ.ច)ដែលអាចនាំទៅសម្រេចក្របខ័ណ្ឌយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រអាស៊ាន២០២១–២០២៥។ការលើកកម្ពស់ស្ត្រីក្នុងការចូលរួមប្រកបដោយអត្ថន័យក្នុងការធ្វើសេចក្តីសម្រេចចិត្តគឺជាការប្តេជ្ញាចិត្តដ៏មានសារៈសំខាន់នៃសេចក្តីថ្លែងការណ៍នេះ។

## ប្រធានបទដែលកំពុងកើតឡើង និងអនុសាសន៍

**ការពង្រឹងគោលនយោបាយ៖** ក្របខ័ណ្ឌគោលនយោបាយនៅក្នុងទូទាំងតំបន់មេគង្គ ជាទូទៅផ្តល់នូវមូលដ្ឋានគ្រឹះគ្រប់គ្រាន់សម្រាប់សមធម៌យេនឌ័រទាក់ទងនឹងដីធ្លី ជាពិសេសនៅប្រទេសវៀតណាម។ ការព្រួយបារម្ភគឺ "ភាពពិការភ្នែកយេនឌ័រ" នៃបទប្បញ្ញត្តិច្បាប់ជាច្រើននៅក្នុងប្រទេសទាំងបួនរួមទាំងបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញមួយចំនួនផងដែរ។

- **អនុសាសន៍៖** ពង្រឹងក្របខ័ណ្ឌគោលនយោបាយតាមរយៈបទប្បញ្ញត្តិច្បាស់លាស់សម្រាប់សមភាពយេនឌ័រ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីហាមឃាត់ឱ្យបានទូលំទូលាយនូវបទដ្ឋានសង្គមដែលរើសអើងលើស្ត្រីភេទ។

**ការកាន់កាប់ដីធ្លីតាមបែបប្រពៃណី៖** ប្រព័ន្ធ និងការអនុវត្តសិទ្ធិកាន់កាប់ដីធ្លីតាមបែបប្រពៃណីមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅទូទាំងតំបន់។ ដំណើរការអនុវត្តជាក់ស្តែងនៃការកំណត់ និងការគូសផែនទីសម្រាប់ការអនុវត្តសិទ្ធិកាន់កាប់ដីធ្លីតាមបែបប្រពៃណី ការកំណត់ព្រំប្រទល់











និងយន្តការអភិបាលកិច្ចអាចមានភាពលំបាក។ ភាពយឺតយ៉ាវក្នុងការដាក់បញ្ចូលនៃកង្វល់ពីយេនឌ័រអាចនឹងមិនទទួលបានការស្វាគមន៍ 'បន្ថែមលើ' វិធីសាស្ត្រដែលមានភាពស្មុគស្មាញរួចស្រេចទៅហើយ។

- **អនុសាសន៍៖** ត្រូវបង្កើនប្រសិទ្ធភាពនិងធានាឱ្យបាននូវការយល់ដឹងដ៏ត្រឹមត្រូវនៃការរៀបចំសិទ្ធិកាន់កាប់ដីធ្លីតាមបែបប្រពៃណី ហើយវិធីសាស្ត្ររួមបញ្ចូលយេនឌ័រពេញលេញមួយត្រូវតែដាក់ឱ្យប្រើប្រាស់តាំងពីដំបូងដោយមានបទប្បញ្ញត្តិច្បាស់លាស់សម្រាប់ការអនុវត្តផងដែរ។

**សិទ្ធិជនជាតិដើម និងជនជាតិភាគតិច៖** នៅទូទាំងតំបន់ក្រុមមនុស្សភាគតិចជាច្រើនមានប្រភពចេញមកពីក្រុមជនជាតិដើម ឬជនជាតិភាគតិច។ ជាញឹកញាប់ ក្រុមមនុស្សទាំងអស់នោះ គឺជាប្រភេទមនុស្សដែលងាយរងគ្រោះបំផុត ហើយស្ត្រីគឺជាជនដែលងាយទទួលរងផលប៉ះពាល់ច្រើនជាងគេ។

- **អនុសាសន៍៖** វិធីសាស្ត្ររដ្ឋបាល និងនីតិវិធីសម្រាប់អភិបាលកិច្ចដីធ្លី គឺចាំបាច់ត្រូវដោះស្រាយជាប្រព័ន្ធនូវភាពងាយរងគ្រោះរបស់ជនជាតិដើមភាគតិច ជាពិសេសស្ត្រីជនជាតិដើមភាគតិច។

**ភាពមិនច្បាស់លាស់ផ្នែកច្បាប់៖** ក្របខ័ណ្ឌច្បាប់នៅទូទាំងតំបន់ នៅមានភាពមិនច្បាស់លាស់ទាក់ទងនឹងស្ថានភាពនៃសិទ្ធិកាន់កាប់ដីធ្លីតាមបែបប្រពៃណីធៀបនឹងសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់។

- **អនុសាសន៍៖** ភាពមិនច្បាស់លាស់ផ្នែកច្បាប់ គួរត្រូវបានដោះស្រាយតាមរយៈការធ្វើកំណែទម្រង់ច្បាប់ដ៏ទូលំទូលាយរួមទាំងនៅកម្រិតនៃបទប្បញ្ញត្តិ និងលក្ខន្តិកៈនានាផងដែរ។

**ការវិនិយោគលើដីធ្លី៖** មានភស្តុតាងបង្ហាញថាស្ត្រីទទួលបានអត្ថប្រយោជន៍កាន់តែតិចតួច និងទទួលរងលើការចំណាយកាន់តែច្រើនពីការវិនិយោគលើដីសម្បទាននៅក្នុងតំបន់ ដោយសារវិសមភាពយេនឌ័រនៅកម្រិតគ្រួសារ និងសហគមន៍។

- **អនុសាសន៍៖** តម្រូវការផ្នែកច្បាប់សម្រាប់ការយល់ព្រមដែលបានទទួលព័ត៌មានជាមុន និងដោយសេរី (FPIC) និងការវាយតម្លៃហេតុប៉ះពាល់សង្គមនិងបរិស្ថាន (ESIA) គឺមានសារៈសំខាន់ណាស់។ ប៉ុន្តែវិធានការគណនេយ្យភាព និងការអនុវត្តច្បាប់ត្រូវតែមានភាពរឹងមាំ ហើយត្រូវអនុវត្តដោយប្រុងប្រយ័ត្នចំពោះវត្តមាន និងសិទ្ធិរបស់ស្ត្រី។ កម្មវិធីដើម្បីពង្រឹងសមត្ថភាពអភិបាលកិច្ចមូលដ្ឋាននឹងក្លាយជាគន្លឹះក៏ដូចជាការដាក់បញ្ចូលនូវវិធានការនានា ដើម្បីធានាឱ្យមានការចូលរួមប្រកបដោយសមធម៌យេនឌ័រនៅក្នុងការយល់ព្រមដែលបានទទួលព័ត៌មានជាមុន និងដោយសេរី (FPIC)។

**រដ្ឋបាលដីធ្លី៖** ប្រទេសទាំងអស់នៅក្នុងតំបន់មេគង្គ បានអនុវត្តការចុះបញ្ជីដីធ្លី និងគំនិតផ្តួចផ្តើមផ្តល់ប័ណ្ណកម្មសិទ្ធិក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ។ គំនិតផ្តួចផ្តើមមួយចំនួនបានចាត់វិធានការ ដើម្បីដោះស្រាយសមធម៌យេនឌ័រ និងសិទ្ធិស្ត្រី ប៉ុន្តែលទ្ធផលទទួលបាន មានភាពចម្រុះគ្នា។

- **អនុសាសន៍៖** ការទទួលស្គាល់កាន់តែច្រើនអំពីភាពខុសគ្នារវាងស្ត្រី និងរវាងបុរស គឺមានសារៈសំខាន់ និងចាំបាច់ណាស់។ សិទ្ធិរបស់មនុស្សដែលមិនទាន់រៀបការ លែងលះ និងស្ត្រីមេម៉ាយត្រូវតែទទួលបានការការពារ ស្របពេលដែលមានជម្រើសកាន់តែច្រើន ត្រូវបានផ្ដល់ជូនដល់គូស្វាមីភរិយាដែលបានរៀបការរួចបន្ថែមពីលើការលើកទឹកចិត្តឱ្យមានសិទ្ធិរួមគ្នាក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។ ដូចគ្នានេះដែរក៏ចាំបាច់ត្រូវត្រួតពិនិត្យមើល និងធ្វើឱ្យវិធានគ្រួសារមានភាពសុខដុម ជាមួយច្បាប់ភូមិបាលទាក់ទងនឹងសមភាពយេនឌ័រក្នុងសិទ្ធិលើអចលនទ្រព្យ។

**គម្លាតនៃការអនុវត្តគោលនយោបាយ៖** មានគោលនយោបាយជាច្រើននៅទូទាំងតំបន់ ដែលត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនិងបានគាំទ្រដល់សមធម៌យេនឌ័រនៅក្នុងអភិបាលកិច្ចដីធ្លី។ យ៉ាងណាក៏ដោយវានៅមានគម្លាតធំនៅឡើយ រវាងគោលនយោបាយទាំងអស់នោះ និងការអនុវត្តជាក់ស្ដែង។ ប្រទេសមេគង្គទាំងបួនដែលជាចំណុច ផ្ដោតនៃចក្ខុវិស័យនេះប្រឈមមុខនឹងកម្រិតផ្សេងៗគ្នានៃសមត្ថភាពផ្នែកបច្ចេកទេស និងធនធានផ្ទៃក្នុង ដើម្បីអនុវត្តគោលនយោបាយ ព្រមទាំងច្បាប់នានា។

- **អនុសាសន៍៖** ពត៌មានអំពីប្រតិបត្តិការ និងនីតិវិធីការងារប្រចាំថ្ងៃលម្អិត, អ្នកអនុវត្តន៍ច្បាប់និងគោលនយោបាយគឺមានសារៈសំខាន់ណាស់ដែលត្រូវកំណត់ និងបែងចែកឱ្យបានច្បាស់លាស់។ ត្រូវធ្វើការសម្របសម្រួលក្នុងចំណោមដៃគូអភិវឌ្ឍន៍ ដើម្បីជៀសវាងនូវការអនុវត្តការងារត្រួតស៊ីគ្នា និងជំរុញឱ្យមានការរួមបញ្ចូលគ្នាផងដែរ។

**អភិបាលកិច្ចដីធ្លីដោយមានការចូលរួម៖** អភិបាលកិច្ចដីធ្លីនៅកម្រិតមូលដ្ឋានគឺមានសារៈសំខាន់ណាស់រួមទាំងតម្រូវការដាក់បញ្ចូលការចូលរួមរបស់សហគមន៍ប្រកបដោយសមធម៌យេនឌ័រនៅក្នុងដំណើរការ និងស្ថាប័ននៃការគ្រប់គ្រងដីធ្លីនៅថ្នាក់មូលដ្ឋាន។

- **អនុសាសន៍៖** ត្រូវមានយន្តការគណនេយ្យភាព និងត្រូវតែអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។ កម្មវិធីបណ្ដុះបណ្ដាល ការកសាងសមត្ថភាព និងគំនិតផ្ដួចផ្ដើមឱ្យមានការយល់ដឹងអំពីយេនឌ័រគឺមានសារៈសំខាន់ណាស់នៅក្នុងការជំរុញដល់ដំណើរការអភិបាលកិច្ចដីធ្លី ដោយមានការចូលរួមប្រកបដោយប្រសិទ្ធភាពដែលនេះមិនគ្រាន់តែជាតំណាងឱ្យអ្នកដឹកនាំនៅក្នុងកម្រិតមូលដ្ឋានប៉ុណ្ណោះទេ។

**បទដ្ឋានសង្គមយេនឌ័រ៖** គុណតម្លៃទាក់ទងនឹងយេនឌ័រ ការអនុវត្ត ប្រព័ន្ធជំនឿ និងទំនៀមទម្លាប់ ជារឿយៗវាជាបទដ្ឋានដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គម ដែលអភិវឌ្ឍបន្តិចម្ដងៗទៅតាមពេលវេលា។ បទដ្ឋានសង្គមទាំងអស់នេះ អាចកាត់បន្ថយកិច្ចខិតខំប្រឹងប្រែងផ្នែកច្បាប់ដើម្បីធានាបាននូវសមធម៌យេនឌ័រទាក់ទងនឹងដីធ្លី។ ការផ្លាស់ប្ដូរបទដ្ឋានសង្គមទាំងអស់នេះ ទោះបីជាមានភាពស្មុគស្មាញជៀសមិនរួចក៏ដោយ ក៏យើងអាចអនុវត្តបានដែរ។

- **អនុសាសន៍៖** អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលអាចធ្វើការរួមគ្នា ជាម្ចាស់ជើងឯកនៃការផ្លាស់ប្ដូរ ទាំងស្ត្រី និងបុរស ដើម្បីលើកកម្ពស់គុណតម្លៃសមធម៌យេនឌ័រ។ ខណៈដៃគូអភិវឌ្ឍន៍អាចជួយគាំទ្រផ្នែកថវិកា និងជំនួយបច្ចេកទេស។



© VinhDao



© Jeff Cagle







**ការពង្រឹងសមត្ថភាពសម្រាប់អនុវត្ត៖** លើសពីនេះទៅទៀត គឺវាកាន់តែចាំបាច់ក្នុងការពង្រឹងសមត្ថភាពរបស់តួអង្គផ្សេងៗគ្នា។ កន្លងមកមានកិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានអនុវត្ត ដើម្បីកែលម្អសមធម៌យេនឌ័រក្នុងការគ្រប់គ្រងដីធ្លីដូចជា ការចុះបញ្ជីដីធ្លី សិទ្ធិទទួលបានយុត្តិធម៌លើការប្រើប្រាស់ដីធ្លី និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងបញ្ហាដីធ្លីជាដើម។ យ៉ាងណាក៏ដោយមកដល់ពេលបច្ចុប្បន្ននេះ នៅតែខ្វះការរួបរួមគ្នាជាផ្លូវមួយ, ការអនុវត្តសកម្មភាពជាមួយគ្នា និងការបន្តអនុវត្តសកម្មភាពដែលមិនសូវមានឥទ្ធិពល។

- **អនុសាសន៍៖** ត្រូវជំរុញឱ្យមានការចូលរួមរបស់សហគមន៍នៅក្នុងការអនុវត្តសកម្មភាពយេនឌ័រ និងដីធ្លីទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ទន្លេមេគង្គ ដើម្បីលើកទឹកចិត្តដល់ការរៀនសូត្រពីគ្នាទៅវិញទៅមក និងការចែករំលែកបទពិសោធន៍គ្នា កិច្ចសហប្រតិបត្តិការក្នុងការតស៊ូមតិលើបញ្ហាសំខាន់ៗ និងការកសាងក្របខ័ណ្ឌច្បាប់ដ៏ចាំបាច់នានាដើម្បីការផ្លាស់ប្តូរប្រកបដោយអត្ថន័យ។

**ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ៖** ខណៈដែលតំបន់មេគង្គជាតំបន់ព្រៃឈើដ៏ច្រើន ការកាប់បំផ្លាញព្រៃឈើ និងការកាប់ឈើខុសច្បាប់នៅតែបន្តកើតមានឡើង។ លើសពីនេះ តំបន់មួយចំនួនងាយរងគ្រោះនឹងការកើនឡើងនៃកម្រិតទឹកសមុទ្រ គ្រោះរាំងស្ងួត សម្ពាធបរិយាកាស និងគ្រោះមហន្តរាយផ្សេងៗទាក់ទងនឹងអាកាសធាតុ។ ចំណែកឯស្ត្រីក៏ស្ថិតក្នុងចំណោមជនងាយរងគ្រោះបំផុតនៅក្នុងសហគមន៍ដែលមានហានិភ័យផងដែរ។

- **អនុសាសន៍៖** វិធីសាស្ត្រក្នុងតំបន់ដោយផ្អែកលើគោលការណ៍ណែនាំរបស់អាស៊ាន ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ គឺចាំបាច់ត្រូវដោះស្រាយផលប៉ះពាល់អវិជ្ជមានលើការកាប់បំផ្លាញព្រៃឈើ និងការប្រែប្រួលអាកាសធាតុលើជនជាតិដើមភាគតិច សហគមន៍ដែលងាយរងគ្រោះផ្សេងទៀត និងស្ត្រីជាជនងាយរងគ្រោះជួបការលំបាកច្រើនក្នុងចំណោមពួកគេ។

**គម្លាតចំណេះដឹងនិងទិន្នន័យ៖** ខណៈពេលដែលមានការកើនឡើងគួរឱ្យកត់សម្គាល់នូវការយល់ដឹងរបស់ពួកយើងអំពីបញ្ហាយេនឌ័រ និងដីធ្លីក៏ដោយ ក៏នៅមានបញ្ហាជាច្រើនទៀតដែលយើងត្រូវធ្វើការសិក្សារៀនសូត្របន្ថែមទៀតផងដែរ។ ដូចជា កង្វះខាតទិន្នន័យអំពីដីធ្លីដែលអាចប្រៀបធៀបគ្នាបាន នៅទូទាំងតំបន់មេគង្គ រួមទាំងទិន្នន័យដែលអាចជឿទុកចិត្តបាន ទិន្នន័យបែងចែកទៅតាមភេទ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលនេះជាបញ្ហាប្រឈមដ៏សំខាន់មួយក្នុងការកំណត់ និងការតាមដានវឌ្ឍនភាពដើម្បីដោះស្រាយបញ្ហាទាំងអស់នោះ។

- **អនុសាសន៍៖** ទិន្នន័យដែលពាក់ព័ន្ធនឹងការបែងចែកទៅតាមភេទ គួរត្រូវបានបង្កើតឡើងដោយយកចិត្តទុកដាក់បំផុត នៅក្នុងដំណើរការរៀបចំបង្កើតកម្មវិធី និងគម្រោងនៅកម្រិតមូលដ្ឋាន ក៏ដូចជានៅក្នុងយន្តការរាយការណ៍ពាក់ព័ន្ធនៅថ្នាក់ជាតិ។ ត្រូវធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតលើផលប៉ះពាល់រយៈពេលវែងនៃការផ្លាស់ប្តូរគោលនយោបាយ ច្បាប់ និងសេដ្ឋកិច្ចសង្គម។

## អនុសាសន៍អាទិភាពកម្រិតខ្ពស់

សមធម៌យេនឌ័រ គឺជាផ្នែកមួយដ៏មានសារៈសំខាន់សម្រាប់អភិបាលកិច្ចដីធ្លីល្អ ហើយយេនឌ័រតែងតែមានគុណតម្លៃជានិច្ច។ ការរំពឹងទុក និងសកម្មភាពអាទិភាពចាំបាច់នានាដែលត្រូវអនុវត្តគឺដើម្បី៖

• ធ្វើឱ្យប្រសើរឡើងនូវការចូលរួមដ៏មានអត្ថន័យរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំសហគមន៍ និងការធ្វើសេចក្តីសម្រេចចិត្តទាំងនៅកម្រិតគ្រួសារ និងនៅកម្រិតសហគមន៍។

• ទទួលស្គាល់ និងអនុវត្តឱ្យបានទូលំទូលាយនូវសិទ្ធិរបស់ស្ត្រីក្នុងការកាន់កាប់/ទទួលមរតកដីធ្លីលើគ្រប់លក្ខខណ្ឌដែលស្មើភាពគ្នាជាមួយបុរស និងមានអំណាចដូចគ្នាជុំវិញការធ្វើសេចក្តីសម្រេចចិត្តលើការប្រើប្រាស់ដីធ្លីរួមទាំងតំណាងនៅក្នុងស្ថាប័នគ្រប់គ្រងដីធ្លីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រាជធានី/ខេត្ត ថ្នាក់មូលដ្ឋាន ដែលជាស្ថាប័នអភិបាលកិច្ច ព្រមទាំងការចូលរួមធ្វើសេចក្តីសម្រេចចិត្តអំពីការវិនិយោគផ្នែកកសិកម្ម។

• លើកកម្ពស់សមត្ថភាពស្ត្រី និងការយល់ដឹងអំពីបញ្ហាសិទ្ធកាន់កាប់ដីធ្លីក្នុងក្របខណ្ឌច្បាប់ដើម្បីឱ្យពួកគេអាចចូលរួមប្រកបដោយអត្ថន័យក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីការប្រើប្រាស់ដីធ្លី។

• ធានាឱ្យស្ត្រីមានលទ្ធភាពទទួលបានសេវារដ្ឋបាលលើផ្នែកដីធ្លី និងប័ណ្ណកម្មសិទ្ធិដីធ្លីក្នុងនាមខ្លួនឯង (មិនគ្រាន់តែក្នុងនាមរួមគ្នា) ទោះបីជាជនអនក្ខរកម្ម ហើយមានឧបសគ្គផ្នែកវប្បធម៌សង្គមក៏ដោយ។

• លើកកម្ពស់ការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតលើបញ្ហាសិទ្ធិទទួលបានដីធ្លីរបស់ស្ត្រី និងសិទ្ធិទទួលបានមរតកនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដោយត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិក្រោមការកាន់កាប់ដីធ្លីតាមបែបប្រពៃណី។

• លើកទឹកចិត្តឱ្យមានការប្តេជ្ញាចិត្តកាន់តែខ្លាំងថែមទៀតនៅក្នុងកម្រិតតំបន់ ដើម្បីឯកភាពគ្នាលើស្តង់ដានិងសូចនាករសម្រាប់ការត្រួតពិនិត្យសមធម៌យេនឌ័រនៃអភិបាលកិច្ចដីធ្លី និងគាំទ្រដល់ការប្រមូលទិន្នន័យជាតិដើម្បីបង្កើតទិន្នន័យបែងចែកទៅតាមភេទដែលអាចប្រៀបធៀបគ្នាបានក្នុងកម្រិតល្អបំផុត ដូច្នេះវឌ្ឍនភាពផ្នែកទិន្នន័យអាចត្រូវបានត្រួតពិនិត្យតាមដាន។

• បង្កើតសហគមន៍ដ៏រស់រវើកមួយសម្រាប់ការអនុវត្តសកម្មភាពការងារទាក់ទង បញ្ហាយេនឌ័រ និងដីធ្លីនៅក្នុងតំបន់ ដើម្បីគាំទ្រដល់ការបង្កើត និងការអនុវត្តវិធានការនានា ដើម្បីកែលម្អសមធម៌យេនឌ័រក្នុងអភិបាលកិច្ចនិងសិទ្ធិទទួលបានដីធ្លី។

នៅកម្រិតនៃគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ប្រទេសទាំងបួនអាចអនុវត្តតាមអនុសាសន៍ដែលទាក់ទងទៅនឹងយេនឌ័រ និងបញ្ហាដីធ្លីដែលបានរៀបចំឡើងដោយគណៈកម្មាធិការ ("ស៊ី-ដ") នៅក្នុងការពិនិត្យជាផ្លូវការចុងក្រោយបំផុតរបស់ពួកគេអំពីប្រទេសកម្ពុជា។ សំដៅចាត់វិធានការដើម្បីបែងចែកឡើងវិញ ឬផ្តល់ដីធ្លីដល់ស្ត្រីដោយត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះជនជាតិដើមភាគតិច ជនជាតិភាគតិច និងស្ត្រីនៅជនបទក្នុងការតាំងលំនៅដ្ឋានក្រៅផ្លូវការ និងត្រូវបង្កើតយន្តការវាយតម្លៃយេនឌ័រជាប្រព័ន្ធអំឡុងពេលអនុម័តឬកែសម្រួលច្បាប់នានា។ នៅកម្រិតនៃកម្មវិធីគ្រប់គ្រងដីធ្លី ការរៀបចំបង្កើត និងការអនុវត្តគម្រោង ប្រទេសទាំងបួនក៏អាចយកចិត្តទុកដាក់បន្ថែមទៀតលើកាបង្កើតថ្មីប្រកបដោយភាពច្នៃប្រឌិត ដោយត្រូវពឹងផ្អែកលើភស្តុតាង និងអនុវត្តល្អជាសកលផងដែរ។

ដៃគូអភិវឌ្ឍន៍មានតួនាទីក្នុងកិច្ចសហការជាមួយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងការបង្កើតសូចនាករសម្រាប់យន្តការត្រួតពិនិត្យច្បាស់លាស់ និងគាំទ្រដល់វិធីសាស្ត្រដែលត្រូវអនុវត្តជាថ្មីម្តងទៀត។ ទាំងនេះរួមបញ្ចូលនូវការត្រៀមខ្លួនរួចជាស្រេច ដើម្បីលើកទឹកចិត្តឱ្យមានការសម្របសម្រួលនៃការអនុវត្តល្អជាលក្ខណៈសកល។ ដូច្នេះដំណោះស្រាយដែលមានលក្ខណៈជាក់លាក់ចំពោះបរិបទនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនឹងត្រូវបានបង្កើតឡើងក្នុងភាពជាដៃគូជាមួយសហគមន៍នៅមូលដ្ឋាន។ ការស្វែងរកអ្វីដែលបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នៅក្នុងបរិបទថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីជំរុញគាំទ្រដល់សមធម៌យេនឌ័រនៅក្នុងបញ្ហាដីធ្លី ដើម្បីឈានទៅសម្រេចលទ្ធផលបានកាន់តែល្អថែមទៀត សម្រាប់ប្រជាជនទាំងអស់នៅក្នុងតំបន់មេគង្គ ទាំងក្មេង ទាំងចាស់ ស្ត្រី និងបុរស រៀបការរួច នៅលីវ អ្នកមាន អ្នកក្រដោយមិនគិតពីការទទួលបានការអប់រំ ពិការភាព/សមត្ថភាព ជាតិសាសន៍ ឬភេទឡើយ។


© VinhDao


© Phuongphoto

ខ្លឹមសារនេះសង្ខេបចេញពីឯកសារដើម៖ Daley, E., Campbell, N. Y., Lowry, J. (2023). ចក្ខុវិស័យស្តីពីយេនឌ័រ និងដីធ្លីក្នុងតំបន់មេគង្គ។ វៀងច័ន្ទន៍៖ អភិបាលកិច្ចដីធ្លីតំបន់មេគង្គ។

អាចអាននៅលើអនឡាញបានតាមរយៈតំណភ្ជាប់នេះ៖ https://www.mrlg.org/publications/outlook-on-gender-and-land-in-the-mekong-region/

ការីនិពន្ធ៖ Renee Chartres, Christophe Gironde, Alice Beban, Micah Ingalls, and Antoine Deligne

រចនាទំព័រ៖ Watcharapol Isarangkul Na Ayuthaya

ស្នាដៃនិពន្ធនេះត្រូវបានការពារកម្មសិទ្ធិបញ្ញានៅក្រោមប្រព័ន្ធ Creative Commons Attribution-NonCommercial-ShareAlike 4.0 International License (CC BY-NC-SA 4.0)

គម្រោងអភិបាលកិច្ចដីធ្លីតំបន់មេគង្គ (MRLG) មានគោលបំណងដើម្បីពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីរបស់កសិករខ្នាតតូចក្នុងតំបន់មេគង្គ ហើយគម្រោងបាននឹងកំពុងអនុវត្តនៅប្រទេសកម្ពុជា ឡាវ ភូមា និងប្រទេសវៀតណាមចាប់តាំងពីខែមេសា ឆ្នាំ២០១៤មក។ គម្រោងអភិបាលកិច្ចដីធ្លីតំបន់មេគង្គគឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលស្វីស តាមរយៈទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) ដោយមានការសហការឧបត្ថម្ភមូលនិធិពីរដ្ឋាភិបាលអាល្លឺម៉ង់ និងរដ្ឋាភិបាលលុចហ្សំបួ។

សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង MRLG, សូមទស្សនាគេហទព័រ www.mrlg.org

## សេចក្តីប្រកាសបដិសេធ

ទស្សនៈមតិ និងការបកស្រាយទាំងឡាយនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ គឺជាទស្សនៈមតិ និងការបកស្រាយរបស់អ្នកនិពន្ធ និងការីនិពន្ធ។ ទស្សនៈមតិ និងការបកស្រាយទាំងនេះមិនត្រូវបានចាត់ទុកថាជាការតំណាងឱ្យទស្សនៈ ឬជំហរផ្លូវការ ឬមិនផ្លូវការរបស់ SDC រដ្ឋាភិបាលអាល្លឺម៉ង់ ឬរដ្ឋាភិបាលលុចហ្សំប៊ួឡើយ។

ផលិតដោយ:

ឧបត្ថម្ភដោយ៖

អនុវត្តដោយ៖

គាំទ្រដោយ៖